00335655

E71

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 06 / 2009
ម៉ោង (Time/Heure): 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ

**Case File/Dossier No. 001/18-07-2007/ECCC/TC**

| | |
|---|---|
| នៅចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០០៩ |
| ចំណាត់ថ្នាក់នៃឯកសារ: | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

# សេចក្តីសម្រេចអំពីទិដ្ឋភាពការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX
Marie-Paule Canizares

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អវតក") ។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោម "តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨។

**រំលឹកឡើងវិញ** "សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីអំពីការកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំវិធានការណ៍ការពារ និងភាគីដែលមានបំណង លើកករណីអញ្ញត្រកម្ម" ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩[1]។

**ក្រោយពីបានទទួល** "ការបញ្ជាក់លើវិធានការការពារចំពោះដើមបណ្តឹងរដ្ឋប្បវេណី" ដែលបានដាក់ជូនដោយតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលស្នើសុំវិធានការការពារទាក់ទិនទៅនឹងតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលតំណាងដោយក្រុមទី១នោះ ("សំណើ")[2]។

## ក. សេចក្តីផ្តើម

១. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន៩៣ នាពេលថ្មីៗនេះត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងលេខ ០០១។ ការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលបានពាក្យសុំចំនួន២៨ នៅដំណាក់កាលស៊ើបអង្កេត។ មុនការចាប់ផ្តើមសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងទទួលបានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀតចំនួន៦៦ ។ អង្គជំនុំជម្រះសាលា

[1] ឯកសារ E9 ("សេចក្តីណែនាំ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩")។

[2] ឯកសារ E9/2។

ដំបូងបានប្រកាសថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយ ក្នុងចំណោមពាក្យសុំទាំងនោះ មិនអាចទទួលយកបាន[3]។

២. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីរ ដែលបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មានបញ្ជាក់នូវសំណើជាក់លាក់សុំវិធានការការពារនានា ដែលទាក់ទិនទៅនឹងសាធារណជន និងភាគីដទៃទៀតនៃដំណើរការនីតិវិធីទាំងនោះ។ អង្គភាពគាំពារសាក្សី និង អ្នកជំនាញ (“WESU”) បានបញ្ចប់ការវាយតម្លៃ អំពីហានិភ័យ របស់ខ្លួនទាក់ទងទៅនិងពាក្យសុំទាំងនោះរួចហើយ ដោយអង្គភាពនេះបានផ្តល់យោបល់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៥ មិនតម្រូវឲ្យមានវិធានការការពារឡើយ[4]។ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការសម្រេចទៅលើសំណើដែលនៅសល់នៅពេលក្រោយ[5]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅសល់ចំនួន៥៩ ទៀត មិនមានការស្នើសុំវិធានការការពារឡើយ។

៣. នៅក្នុងសេចក្តីណែនាំចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី (ពោលគឺដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨ រូប ដែលបានចូលរួមក្នុងសំណុំរឿងក្នុងអំឡុងដំណាក់កាលស៊ើបអង្កេត) ដែលមានបំណងស្នើសុំវិធានការការពារនៅដំណាក់កាលជំនុំជម្រះក្តីនៃដំណើរការនីតិវិធី ត្រូវដាក់ពាក្យស្នើសុំយ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០០៩។ អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលសំណើសុំបែបនេះ នៅក្នុងអំឡុងកាលបរិច្ឆេទនេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងក៏បានណែនាំបន្ថែមទៀត ដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថ្មីៗ ដែលមានបំណងស្នើសុំវិធានការការពារ ត្រូវដាក់ពាក្យសុំយ៉ាងយូរត្រឹមថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩។ តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ បានដាក់សំណើសុំរបស់ខ្លួននៅត្រឹមកាលបរិច្ឆេទនេះ។ មិនមានដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតដាក់នូវសំណើជាលាយលក្ខណ៍អក្សរនៅក្នុងអំឡុងពេលវេលា ដែលបានកំណត់ឡើយ។

៤. នៅក្នុងសវនាការបឋមថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសបន្ថែមទៀតដល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្ប

---

[3] ពាក្យសុំរបស់តំណាងដើមបណ្តឹងរដ្ឋប្បវេណី E2/36។ សេចក្តីណែនាំអំពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះអ្នកដាក់ពាក្យសុំ E2/36 E2/51 និង E2/69 ដែលបានចេញនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៩ ឯកសារ E2/94/2។

[4] តំណាងដើមបណ្តឹងរដ្ឋប្បវេណី E2/61, E2/63, E2/64, E2/65 និង E2/66 (ដែលបានដាក់ជូនដោយសម្ងាត់បំផុត)។

[5] តំណាងដើមបណ្តឹងរដ្ឋប្បវេណី E2/62 និង E2/89 (ដែលបានដាក់ជូនដោយសម្ងាត់បំផុត)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

វេណីទាំងអស់ ឲ្យធ្វើសេចក្តីសន្និដ្ឋានស្តីអំពីវិធានការការពារ។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ បានថ្លែងបញ្ជាក់ជាថ្មីអំពីសំណើជាលាយលក្ខណ៍អក្សររបស់ខ្លួន[6]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ បានរំលឹកឡើងវិញអំពីសំណើរបស់ខ្លួនស្នើសុំវិធានការការពារទាក់ទិនទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ E2/89[7] ដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះកំពុងតែរង់ចាំសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[8]។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតមិនបានស្នើសុំវិធានការការពារណាមួយ ដែលតម្រូវឲ្យមាននូវសេចក្តីសម្រេចពីអង្គជំនុំជម្រះសាលាដំបូងនៅដំណាក់កាលនេះឡើយ[9]។ នៅក្នុងសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជាវិធានការបណ្តោះអាសន្ន រាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នឹងត្រូវបានគេហៅឈ្មោះតាមលេខយោងឯកសារនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើមរបស់ពួកគេ[10]។

## ខ. សេចក្តីសន្និដ្ឋាន

៥. នៅក្នុងសំណើរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ធ្វើសេចក្តីសន្និដ្ឋានថា រាល់តំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គួរទទួលបានវិធានការការពារ ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”)។ វិធានការការពារនោះ នឹងត្រូវបន្តយកមកអនុវត្តដូចគ្នាក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីទាំងមូល លុះត្រាតែដើមបណ្តឹងរដ្ឋប្បវេណីបោះបង់សិទ្ធិមិនទទួលយកវិធានការការពារទាំងនោះ ឬវិធានការការពារនោះមានការ ផ្លាស់ប្តូរ ឬលុបចោលដោយអង្គជំនុំជម្រះសាលាដំបូង[11]។ ជាការគាំទ្រនូវសំណើនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋ

---

[6] ប្រតិចារិក (“ប”) សវនាការបឋម ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ១៨-១៩ និង ២៣-២៤។

[7] ប ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ (សវនាការបឋម) ទំព័រ២២ បន្ទាត់១៥-១៥ និងទំព័រ២៤។

[8] ជើងទំព័រខាងលើ កថាខណ្ឌ៣ ជើងទំព័រ៥។

[9] នៅពេលដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ និងក្រុមទី៤ មិនបានស្នើសុំវិធានការការពារ តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ បានរក្សាសិទ្ធិពួកគេក្នុងការស្នើសុំវិធានការនៅពេលអនាគត ប្រសិនបើមានករណីចាំបាច់ (ប ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ (សវនាការបឋម) ទំព័រ១៩ (បន្ទាត់១៩-២៥) ទំព័រ២០ (បន្ទាត់៦-៧) និងទំព័រ២៣ (បន្ទាត់១៨-១២))។

[10] ប ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ (សវនាការបឋម) ទំព័រ១៥ បន្ទាត់២១-២៥។

[11] សំណើ កថាខណ្ឌ៤។

ប្បវេណីក្រុម១ បានសំអាងលើមាត្រា៤.១ និងមាត្រា៤.៤ នៃសេចក្តីណែនាំអនុវត្ត ស្តីអំពីវិធានការការពារ[12]។

៦. យោងតាមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សេចក្តីសម្រេចមុនៗរបស់ ក.ស.ច.ស បានផ្តល់នូវវិធានការផ្សេងៗមួយចំនួន រួមទាំងការចេញដីកានានាការពារមិនឱ្យលេចព័ត៌មានអំពីអត្តសញ្ញាណដល់សាធារណជនឡើយ ដែលវិធានការនោះយកមកអនុវត្តចំពោះរាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដោយមិនគិតអំពីពេលវេលាដែលពាក្យសុំទាំងនោះដាក់ជូននៅពេលណានោះទេ[13]។ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានវិធានការការពារ ដែលចេញដោយ ក.ស.ច.ស ទាំងអស់គ្នាទេ ក្នុងករណីនេះ វិធានការដូចគ្នាទៅនឹងវិធានការការពារ គួរត្រូវបានដាក់ចេញដោយអង្គជំនុំជម្រះសាលាដំបូង[14]។

## គ. សំអាងហេតុ

៧. "សេចក្តីសម្រេចអំពីវិធានការការពារ" របស់ ក.ស.ច.ស បានបដិសេធនូវសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យមានវិធានការការពារចំពោះជនរងគ្រោះ សាក្សី និងតតិយជន ដែលមានចំនួនដ៏ច្រើននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។ ទោះបីជាត្រូវចាត់វិធានការឱ្យបានសមស្របក្នុងការធានាការពារជនរងគ្រោះ និងសាក្សីទាំងអស់ក៏ដោយ ក.ស.ច.ស បានកត់សំគាល់ថា វិធានការដែលមិនមានការវិនិច្ឆ័យឱ្យបានត្រឹមត្រូវទាក់ទិនទៅនឹងចំនួនបុគ្គលដែលមិនមានកម្រិត ការមិនបញ្ជាក់មូលហេតុច្បាស់លាស់ បានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសំខាន់ជាសារវ័ន្តរបស់ជនជាប់ចោទនៅក្នុងដំណើរក្តីព្រហ្មទណ្ឌ[15]។ នៅពេលដែលដីកាសម្រេចនោះ មិនបានប៉ះពាល់ដល់សិទ្ធិរបស់ភាគី ឬបុគ្គលផ្សេងទៀតនៅក្នុងការស្នើសុំវិធានការ

---

[12] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០៣/២០០៧ Rev. 1។

[13] សំណើ កថាខណ្ឌ៧-៨ (បញ្ជាក់ពីដីកាសម្រេច D6 (ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧) ដីកាសម្រេច D12/VI (ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៧) និង ដីកាសម្រេច D98/4 (ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៨)។

[14] ដូចឯកសារយោងខាងលើ កថាខណ្ឌ៥។

[15] សេចក្តីសម្រេចអំពីវិធានការការពារ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ដីកាសម្រេច D6 ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ១ (ដោយកត់សំគាល់ថា សំណើនោះមិនបានបញ្ជាក់ឈ្មោះរបស់បុគ្គលដែលពាក់ព័ន្ធឡើយ ឬក៏មិនបានបញ្ជាក់ថាប្រសិនបើមិនមានវិធានការការពារទេ នោះនឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិត និងសន្តិសុខរបស់បុគ្គលរាប់រយនាក់ ដែលមានយោងនៅក្នុងសំណើនោះឡើយ។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

ការពារចាំបាច់ណាមួយទេ ក.ស.ច.ស បានធ្វើការបញ្ជាក់ថា ពាក្យសុំនោះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីអត្តសញ្ញាណរបស់ភាគី និងបុគ្គលទាំងអស់ ដែលត្រូវទទួលវិធានការការពារ និងត្រូវបញ្ជាក់ថា ប្រសិនបើមិនមានវិធានការការពារទេនោះ អាយុជីវិត និងសុខមាលភាពរបស់បុគ្គលទាំងនេះ ឬក្រុមគ្រួសាររបស់ពួកគេនឹងស្ថិតក្នុងគ្រោះថ្នាក់[16]។ យុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏បានបង្ហាញផងដែរថា វិធានការការពារត្រូវបានផ្តល់ឱ្យតាមករណីនីមួយៗ នៅពេលដែលសំណើនោះមានព័ត៌មានគ្រប់គ្រាន់ស្តីអំពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ និងការបញ្ជាក់ដ៏លំអិតអំពីគ្រោះថ្នាក់ ឬព្យសនកម្ម ដែលអ្នកដាក់ពាក្យសុំ ឬក្រុមគ្រួសាររបស់ពួកគេនឹងប្រឈម។ បន្ថែមពីនេះទៀត ពាក្យសុំនោះចាំបាច់តម្រូវឱ្យមានបញ្ជាក់ពីការភ័យខ្លាចដ៏ពិតប្រាកដរបស់អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងអត្ថិភាពនៃមូលហេតុដ៏ច្បាស់លាស់ចំពោះការភ័យខ្លាចនោះ[17]។

៨. សេចក្តីសម្រេចជាបន្តបន្ទាប់របស់ ក.ស.ច.ស ក៏បានបញ្ជាក់ម្តងទៀតអំពីលក្ខណៈវិនិច្ឆ័យជាអប្បបរមាក្នុងការផ្តល់វិធានការការពារ និងបង្ហាញថា វិធានការការពារតែងត្រូវបានផ្តល់ជូនដល់បុគ្គលដែលត្រូវបានគេកំណត់ ដោយឈរលើមូលដ្ឋាននៃហានិភ័យដែលបានបញ្ជាក់ច្បាស់លាស់។ នៅក្នុងសេចក្តីសម្រេចបន្ថែមរបស់ខ្លួន ស្តីអំពីសំណើសុំវិធានការការពារលេខ D12/VI ក.ស.ច.ស បានបដិសេធសំណើដែលធ្វើឡើងជាថ្មីពីការិយាល័យសហព្រះរាជអាជ្ញា ដោយឈរលើហេតុផលថា សំណើនោះមិនបានបំពេញឱ្យបានកម្រិតជាក់លាក់តាមតម្រូវការ ហើយសំណើ

[16] ដូចឯកសារយោងមុន។

[17] សូមអាន ឧទាហរណ៍ ព្រះរាជអាជ្ញា ទល់នឹង Gatete សំណុំរឿងលេខ ICTR-2000-61-I សេចក្តីសម្រេចអំពីសំណើរបស់មេធាវីការពារក្តីសុំឱ្យមានការការពារសាក្សី ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ (អង្គជំនុំជម្រះសាលាដំបូង) កថាខណ្ឌ២។ ព្រះរាជអាជ្ញា ទល់នឹង Renzaho សំណុំរឿងលេខ ICTR-97-31-DP សេចក្តីសម្រេចអំពីសំណើរបស់មេធាវីការពារក្តីស្នើសុំវិធានការការពារ (អង្គជំនុំជម្រះសាលាដំបូង) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ កថាខណ្ឌ៤។ ព្រះរាជអាជ្ញា ទល់នឹង Bagosora et al. សំណុំរឿងលេខ ICTR-96-7 សេចក្តីសម្រេចអំពីសំណើរបស់ Bagosora ស្នើសុំការការពារសាក្សី (អង្គជំនុំជម្រះសាលាដំបូង) ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ២។ ព្រះរាជអាជ្ញា ទល់នឹង Milosevic សេចក្តីសម្រេចទីពីរអំពីសំណើរបស់អយ្យការស្នើសុំវិធានការការពារសម្រាប់សាក្សីដែលងាយទទួលផលប៉ះពាល់ (អង្គជំនុំជម្រះសាលាដំបូង) ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០២។ ទោះបីជាមានការសំដៅទៅលើការការពារសាក្សីដែលបង្ហាញវត្តមាននៅពេលជំនុំជម្រះក្តីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ច្បាប់យុត្តិសាស្ត្រនេះអាចផ្តល់គោលការណ៍ណែនាំដូចគ្នាផងដែរ ចំពោះការការពារតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។



E C C C • E T C
TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

នោះមិនបានបញ្ជាក់ថា ប្រសិនបើមិនមានវិធានការការពារទេ នោះអាយុជីវិត និងសន្តិសុខរបស់អ្នកដាក់ពាក្យសុំនីមួយៗនឹងស្ថិតនៅក្នុងគ្រោះថ្នាក់បែបណា[18]។ សេចក្តីសម្រេចនោះក៏បានធ្វើការកត់សំគាល់ផងដែរអំពីលក្ខណៈវិនិច្ឆ័យមិនលំអៀង ដែលអនុវត្តដោយអង្គការសហប្រជាជាតិក្នុងការវាយតម្លៃតំណាក់កាលសន្តិសុខបច្ចុប្បន្នក្នុងប្រទេសកម្ពុជា និងរយៈពេលដែលបានគន្លងផុតទៅចាប់តាំងពីការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងយុត្តាធិការរបស់តុលាការ ដែលសាក្សី និងជនរងគ្រោះទាំងអស់នោះអាចត្រូវបានកោះហៅដើម្បីធ្វើសក្ខីកម្ម[19]។ សេចក្តីសម្រេចនោះក៏បានវាយតម្លៃបន្ថែមទៅលើការភ័យខ្លាច និងការស្ទាក់ស្ទើរដែលបានលើកឡើងចំពោះជនរងគ្រោះ និងសាក្សីខ្លះក្នុងការធ្វើសក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក ថាមិនអាចយកជាការបាន[20]។ ចុងក្រោយ សេចក្តីសម្រេចនេះបានកត់សំគាល់ថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញ មានការយល់ឃើញផ្សេងអំពីហានិភ័យដែលមានលក្ខណៈទូទៅចំពោះសន្តិសុខរបស់ជនរងគ្រោះ និងសាក្សីសំខាន់ៗ ព្រមទាំងគ្រោះថ្នាក់នាពេលថ្មីៗនេះ។ ការវាយតម្លៃនេះបានបង្ហាញថា សាក្សីមួយចំនួនបានត្រៀមលក្ខណៈរួចហើយដើម្បីធ្វើសក្ខីកម្មជាសាធារណៈ ហើយថា ចំពោះសាក្សីភាគច្រើនកម្រិតហានិភ័យមានលក្ខណៈទាប[21]។ នៅក្នុងដីកាសម្រេចលើវិធានការការពារលេខ D98 ក.ស.ច.ស ក៏បានបដិសេធស្រដៀងគ្នានេះដែរនូវសំណើសុំវិធានការការពារនានា ចំពោះដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីររូប ដោយផ្អែកលើកត្តាជាច្រើន ដែលក្នុងនោះរួមមានកត្តាដែលថាដើមបណ្តឹងរដ្ឋប្បវេណី មួយចំនួនមានសាវតាជាអ្នកខ្ពង់ខ្ពស់ មិនមានការគំរាមកំហែងណាមួយរហូតមកដល់ពេលនេះចំពោះការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មិនមានការបង្ហាញអំពីរាមកំហែងថ្មីៗចំពោះពួកគេ ព្រមទាំងការផ្តល់យោបល់របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញថាមិនចាំបាច់មានវិធានការការពារឡើយ[22]។

---

[18] សេចក្តីសម្រេចបន្ថែមអំពីសំណើសុំវិធានការការពារ (D12/VI) ក.ស.ច.ស ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ៧។

[19] ដូចឯកសារយោងមុន កថាខណ្ឌ១៣។

[20] ដូចឯកសារយោងមុន កថាខណ្ឌ១៤។

[21] ដូចឯកសារយោងមុន កថាខណ្ឌ១៥ (កត់សំគាល់ថា សាក្សីសំខាន់ៗជាច្រើនត្រូវសាធារណជនស្គាល់រួចហើយតាមរយៈការប្រកាសជាសាធារណៈកាលពីលើកមុនៗតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ហើយថា ការបញ្ចូលឈ្មោះរបស់ពួកគេជាសាក្សីសំខាន់ៗ ហាក់បីដូចជាបង្កើតនូវហានិភ័យបន្ថែមទៀតដល់ពួកគេ)។

[22] ដីកាស្តីអំពីវិធានការការពារ (D98) ក.ស.ច.ស ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ១.២-១.២.៦ និង២.៦។ ទោះបីជាយ៉ាងណាក៏ដោយ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានផ្តល់យោបល់ថា អត្តសញ្ញាណរបស់តំណាង



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

៨. សេចក្តីសម្រេចរបស់ ក.ស.ច.ស ដែលត្រូវបានលើកយកមកបញ្ជាក់ដើម្បីគាំទ្រដល់សំណើនេះ គឺមិនមានវិធានការការពារ ដែលអាចត្រូវបានយកមកអនុវត្តជាក់ស្តែងចំពោះដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងករណីនេះឡើយ។ ទោះបីជា ក.ស.ច.ស បានបញ្ជាក់ជាថ្មីដោយមិនមានការកែប្រែថា បុគ្គលណាដែលមានសិទ្ធិពិនិត្យសំណុំរឿងត្រូវជាប់កាតព្វកិច្ចវិជ្ជាជីវៈរក្សាការសម្ងាត់ មិនធ្វើឱ្យព័ត៌មានដែលទទួលបានពីការពិនិត្យសំណុំរឿងលេចលឺដល់សាធារណជនក៏ដោយ ប៉ុន្តែការបញ្ជាក់នេះគឺគ្រាន់តែជាការអនុវត្តន៍តាមលក្ខណៈសម្ងាត់នៃកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការតែប៉ុណ្ណោះ[24]។ ការរក្សាការសម្ងាត់នៃកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ គឺមានលក្ខណៈខុសគ្នាពីដំណើរការនីតិវិធីជំនុំជម្រះក្តី ដែលគេសន្មតថាដំណើរការនីតិវិធីជំនុំជម្រះក្តីមានលក្ខណៈជាសាធារណៈ។ លើសពីនេះទៀត ក.ស.ច.ស ខ្លួនឯងមិនបានធ្វើការពិចារណាថា វិធានការដែលខ្លួនបានអនុម័ត នឹងបន្តមានប្រសិទ្ធភាពក្នុងដំណាក់កាលទាំងមូលនៃការជំនុំជម្រះក្តីឡើយ។ ផ្ទុយទៅវិញ ក.ស.ច.ស បានបញ្ជាក់ថា វាជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយមានតែអង្គជំនុំជម្រះសាលាដំបូងតែមួយគត់ ក្នុងការសម្រេចថាតើត្រូវដាក់កម្រិតជាយថាហេតុ ចំពោះសិទ្ធិបើកសវនាការជាសាធារណៈនៅដំណាក់កាលជំនុំជម្រះក្តី ឬយ៉ាងណា ដោយអនុលោមតាមគោលការណ៍តទល់គ្នា និងគោរពដល់សិទ្ធិក្នុងការការពារក្តី[25]។

---

ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូច មិនត្រូវផ្សព្វផ្សាយដល់សាធារណជនទេ ដោយសារតែជាលក្ខណៈកម្មវត្ថុពិសេសរបស់ភាគីទាំងនេះ (ដូចឯកសារយោងមុន កថាខណ្ឌ១.២.៣-២.៥)។

[24] សេចក្តីសម្រេចបន្ថែមស្តីអំពីសំណើសុំវិធានការការពារ (D12/VI) ក.ស.ច.ស ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ១៨ និងកថាខណ្ឌ៣ (បទបញ្ញត្តិ) និងដីកាស្តីអំពីវិធានការការពារ (D98) ក.ស.ច.ស ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ២.៩។

[25] ដីកាស្តីអំពីវិធានការការពារ (D98) ក.ស.ច.ស ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ២-៧។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

00335663



E71

១០. វាជាលទ្ធផលនៃការបដិសេធរបស់ ក.ស.ច.ស ទៅលើសំណើសុំវិធានការការពារទាំងអស់នៅក្នុងករណីនេះ ដែលធ្វើឱ្យមាត្រា៤.១ និងមាត្រា៤.៤ នៃសេចក្តីណែនាំអនុវត្តស្តីអំពីវិធានការការពារ មិនអាចយកមកអនុវត្តបាន[26]។

១១. ក្នុងខណៈដែលមិនមានវិធានការការពារ ដែលអាចអនុវត្តបានក្នុងដំណាក់កាលនេះ អនុលោមតាមសេចក្តីសម្រេចរបស់ ក.ស.ច.ស អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការសម្រេចថាតើអាចត្រូវដាក់ចេញវិធានការការពារណាមួយ អនុលោមតាមសំណើនេះ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនមានព័ត៌មានស្តីអំពីអត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗដែលបានដាក់ដោយក្រុមទី១ និងកាលៈទេសៈជាក់លាក់ដែលចាំបាច់ត្រូវចេញវិធានការការពារដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះនៅក្នុងសំណើនេះឡើយ។ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ក្រុមទី១ ក៏មិនបានផ្តល់ភស្តុតាងបង្ហាញថាសុវត្ថិភាពដែលដើមបណ្តឹងរដ្ឋប្បវេណីមានការព្រួយបារម្ភមានលក្ខណៈសមហេតុផលឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនមានការបង្ហាញឱ្យបានជាក់លាក់អំពីភាពចាំបាច់សម្រាប់វិធានការការពារឡើយ ទាក់ទិនទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយក្រុមទី១។

១២. ចំពោះពាក្យស្នើសុំវិធានការការពារជាក់លាក់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីលេខ E2/61, E2/63, E2/64, E2/65 និង E2/66 អង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញផងដែរថា សំណើទាំងនេះមិនមានសំអាងហេតុត្រឹមត្រូវទេ។ ពាក្យស្នើសុំទាំងនេះមិនមានព័ត៌មានលំអិតគ្រប់គ្រាន់ អំពីស្ថានភាពជាក់លាក់ដែលត្រូវចេញដីកាសម្រេចបែបនេះឡើយ។ លើសពីនេះទៀត ការវាយតម្លៃអំពីហានិភ័យ របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះអាចប្រឈប មិនបានបង្ហាញ ឬបញ្ជាក់ពីការគំរាមកំហែងជាក់លាក់ ឬក៏សន្តិសុខដែលគួរឱ្យព្រួយបារម្ភឡើយ ហើយបានផ្តល់យោបល់ថាមិនចាំបាច់មានវិធានការការពារឡើយ។ មិនមានការបង្ហាញអំពីភាពចាំបាច់ចំពោះវិធានការការពារដែលបានស្នើសុំ ទាក់ទិនទៅនឹងដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ។

---

[26] មាត្រា៤.១ និង ៤.៤ នៃសេចក្តីណែនាំអនុវត្តចែងថា វិធានការការពារ នៅពេលដែលចេញមកនោះ ត្រូវបន្តអនុវត្តដូចគ្នាក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីទាំងមូល នៅក្នុងករណីដែលពាក់ព័ន្ធ លុះត្រាតែមានការផ្លាស់ប្តូរ ឬលុបចោល ដោយសហចៅក្រមស៊ើបអង្កេត ឬក៏បានទទួលដោយអង្គជំនុំជម្រះសាលាដំបូង។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE C C C E T C

១៣. **យល់ឃើញថា** វិធានការការពារមិនត្រូវបានផ្តល់ជូនឡើយ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងលេខ ០០១ ដែលបានស្នើសុំវិធានការការពារ (ពោលគឺដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាង ដោយក្រុមទី១ និងដើមបណ្តឹងរដ្ឋប្បវេណីលេខ E2/61, E2/63, E2/64, E2/65 និង E2/66) ហើយ **កត់សំគាល់ឃើញថា** វិធានការការពារមិនត្រូវបានស្នើសុំ ចំពោះតំណាង ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតឡើយនៅក្នុងសំណុំរឿងលេខ ០០១។

## ឃ. សេចក្តីសម្រេច

**តាមរយៈសំអាងហេតុដែលបានលើកឡើងខាងលើ** អង្គជំនុំជម្រះសាលាដំបូង **សម្រេចៈ**

**បដិសេធ** សំណើនេះ។

**ពន្យារនូវការ** សម្រេចសេចក្តីរបស់ខ្លួនទាក់ទិនទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីលេខ E2/62 និង E2/89 ។

**បង្គាប់ឲ្យ** ផ្នែកគ្រប់គ្រងតុលាការធ្វើចំណាត់ថ្នាក់ជាថ្មីឡើងវិញ ចំពោះពាក្យស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខ E2/61, E2/63, E2/64, E2/65 និង E2/66 ដែលថាជាការសម្ងាត់ ហើយត្រូវជូនដំណឹងអំពីពួកគេ ដល់ភាគីដទៃទៀតនៅក្នុងគ្រប់ដំណើរការនីតិវិធី។

**បង្គាប់ថា** សម្រាប់ដំណើរការនីតិវិធីជាសាធារណៈ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុង សំណុំរឿងលេខ០០១ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ (លើកលែងតែដើមបណ្តឹងរដ្ឋប្ប វេណីលេខ E2/62 និង E2/89) ចាប់ពីពេលនេះតទៅ នឹងត្រូវបានហៅដោយប្រើឈ្មោះបាន ហើយ ប្រសិនបើចាំបាច់ ត្រូវប្រើលេខយោងដូចមានក្នុងឯកសារពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធ។

ភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**